

ដោយអែលឌើរ
វើន ភី ស្ដានហ្វីល
ក្នុងកូរ៉ុមនៃពួកចិតសិបនាក់

# ចៀម និងអ្នកគង្វាលរបស់វា

*« ព្រះយេហូវ៉ាទ្រង់ជាអ្នកគង្វាលខ្ញុំ »* ( *ទំនុកដំកើង ២៣:១* ) ។

ខ្ញុំបានធំឡើងនៅវាលចិញ្ចឹមគោក្នុងរដ្ឋម៉ុនតាណា ស.រ.អា. ។ ពួកយើងក៏មានចៀមប្រហែល ៣០០ ក្បាលនៅវាលចិញ្ចឹមសត្វនោះ ។ ម្ដាយខ្ញុំចិញ្ចឹមវា ដើម្បីពួកយើងអាចរកប្រាក់ដើម្បីបម្រើបេសកកម្មរបស់យើង ។

កិច្ចការរបស់ខ្ញុំគឺត្រូវមើលថែកូនចៀម ដែលគ្មានមេមើលថែពួកវា ។ ពេលចៀមមួយមានកូនលើសពីមួយ ជួនកាលមេចៀមនោះពុំមើលថែកូនចៀមទាំងអស់របស់វាបានទេ ។ អញ្ចឹងខ្ញុំជាអ្នកមើលថែកូនចៀមទាំងអស់នោះ ។ មានកូនចៀមបែបនេះប្រហែលពី ៥ ទៅ ១០ ក្បាលរៀងរាល់ឆ្នាំ ។

រៀងរាល់ថ្ងៃ ខ្ញុំបើកឡានតូចពណ៌ខៀវរបស់យើងដែលគេហៅ Volkswagen Beetle ទៅវាលស្មៅ ហើយចុចសីផ្លេរ ។ បន្ទាប់មកខ្ញុំបើកទ្វារឡាន ។ កូនចៀមទាំងនោះនឹងចេញពីគ្រប់កន្លែងទាំងអស់នៅក្នុងវាលនោះ ។ ពួកវាស្គាល់សំឡេងឡាន Volkswagen ដ៏ចាស់នោះ ។ ពួកវានឹងលោតឡើងលើគូថឡាន ហើយខ្ញុំនឹងដឹកវាទៅជង្រុក ហើយផ្ដល់ចំណីឲ្យវា ។

យើងទាំងអស់គ្នាដូចជាកូនចៀមតូចៗទាំងនោះដែរ ។ យើងរស់នៅកន្លែងផ្សេងៗពីគ្នា ហើយមានឧបសគ្គផ្សេងៗគ្នានៅក្នុងជីវិតយើង ។ ប៉ុន្តែព្រះយេស៊ូវកំពុងឈោងទៅជួយយើងម្នាក់ៗ ។ ខ្ញុំអាចរៀនស្ដាប់សំឡេងរបស់ទ្រង់ ។ យើងអាចងាកទៅរកទ្រង់ទូលសូមការលួងលោម និងសុវត្ថិភាព ។ យើងអាចទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់ពីទ្រង់ និងព្រះវរបិតាសួគ៌ ។

ពេលខ្ញុំបានសម្លឹងមើលទៅព្រះយេស៊ូវដូចជាអ្នកគង្វាលក្នុងជីវិតខ្ញុំ នោះជីវិតខ្ញុំបានផ្លាស់ប្ដូរ ។ ពេលយើងដាក់ជីវិតយើងនៅក្នុងព្រះហស្តរបស់ព្រះអង្គសង្គ្រោះ នោះយើងនឹងទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ទ្រង់ ហើយរៀនទុកចិត្តទ្រង់ ។ ●

*ដកស្រង់ពីការសម្ភាសមួយជាមួយ គ្រីស្ទីណា ក្រូស្លែន ។*

